# សេចក្តីជូនដំណឹង

**ស្តីពី**

## ការរក្សាចំណាត់ថ្នាក់ B+/Stable/B របស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) ជាធនាគារពាណិជ្ជទីមួយដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនៅកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ភ្នាក់ងារវាយតម្លៃអន្តរជាតិ **Standard & Poor’s (S&P) Global Ratings** បានរក្សាចំណាត់ថ្នាក់ "**B+/Stable/B**" សម្រាប់ធនាគារ អេស៊ីលីដា។

ការរក្សាបាននូវចំណាត់ថ្នាក់នេះសបញ្ជាក់ថា ធនាគារ អេស៊ីលីដា រក្សាបាននូវស្ថិរភាពប្រវត្តិហិរញ្ញវត្ថុរបស់ខ្លួនក្នុងរយៈពេលវែង ជាមួយនឹងទ្រនាប់ដើមទុនគ្រប់គ្រាន់ ជួយឱ្យធនាគារ អេស៊ីលីដា រក្សាបាននូវស្ថិរភាពដើមទុនរបស់ខ្លួនសម្រាប់បង្ការផលប៉ះពាល់សេដ្ឋកិច្ចពីវិបត្តិកូវីដ-១៩ និងឧបសគ្គផ្សេងៗ ជាច្រើន ក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ច។ បន្ថែមលើនេះ ធនាគារ អេស៊ីលីដា មានមូលដ្ឋានប្រាក់បញ្ញើដ៏សម្បូរបែប រួមទាំងសេវាបើកប្រាក់បៀវត្ស តាមរយៈបច្ចេកវិទ្យាឌីជីថលលេចធ្លោ និងបណ្តាញប្រតិបត្តិការទូលំទូលាយ។ កត្តាទាំងអស់នេះបានឆ្លុះបញ្ចាំងពីភាពរឹងមាំជាវិជ្ជមាននៃបណ្តាញធុរកិច្ចរបស់ធនាគារ អេស៊ីលីដា ចំពោះគុណភាពនៃដើមទុន និងប្រាក់ចំណេញ ដែលអាចរក្សាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ២កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ធនាគារ អេស៊ីលីដា ភីអិលស៊ី ACLEDA BANK PLC.

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP